- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ . -**

ត្រូវបានតែងតាំងទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោមៈ

១- លោក **ឃុត សាខន** ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយករង

២- លោក **ខឡូ វ៉ូដាធុល** ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយករង

៣- លោកស្រី **ទាប ស៊ីអ៊ុយ** ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយករង

៤- លោកស្រី **អ៊ុំ សុជាតិ** ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយករង

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>ចម្លងជូន</u>** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំង សមាសភាព នៃគណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤•ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

### សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងជាសមាជិកភាពនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត | **ប៊ុន រ៉ានី ហ៊ុន សែន** | | ប្រធានកិត្តិយស |
| ២- លោកជំទាវវេជ្ជ. | **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | ប្រធាន |
| ៣- លោកជំទាវ | **ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោកជំទាវ | **ម៉ិញ្ញ កុសនី** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- លោកជំទាវ | **ច័ន្ទ ធី** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | អនុប្រធាន |
| ៦- លោកជំទាវ | **ង៉ូ ម៉ឺនអេង** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៧- លោកជំទាវ | **ស៊ើង សរសុចិត្តា** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨- លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិកា |

| | | | |
|---|---|---|---|
| ៩- លោកជំទាវ | **សម មុន្នីកា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិកា |
| ១០- លោកជំទាវ | **ទូច សារ៉ុម** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិកា |
| ១១- លោកជំទាវ | **ម៉ាលី សុជាតា** | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិកា |
| ១២- លោកជំទាវ | **មាសសាឯម ដានី** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ១៣- លោកជំទាវ | **កែវ ចរិយា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| ១៤- លោកជំទាវ | **ទ្រឹង មុទុមរឡើ** | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិកា |
| ១៥- លោកជំទាវ | **ច័ន្ទ ហារ៉ាន់វឌ្ឍី** | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៦- លោកជំទាវ | **ធន់ សារអ៊ីម** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៧- លោកជំទាវ | **យ៉យ នីតា** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ១៨- លោកជំទាវ ឧត្តមសេនីយ៍ឯក | **យក់ សុខា** | អគ្គស្នងការរងនគរបាលជាតិ | សមាជិកា |
| ១៩- លោក វរសេនីយ៍ឯក | **ស៊ិន ស៊ីថា** | នាយការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ | សមាជិក |
| ២០- លោកស្រី | **ម៉ក វណ្ណាស៊ីថា** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិកា |

**ប្រការ២:** សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មានភារកិច្ចអនុវត្តការងារ ទៅតាមការតម្រង់ទិសដៅនៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ទទួលបានលទ្ធផលល្អប្រសើរ និងអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាដ្ឋានព្រឹទ្ធសភា
-អគ្គលេខាដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៦ - សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មាធិការតាមវិស័យ
## នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើតអនុគណៈកម្មាធិការតាមវិស័យ ដូចខាងក្រោម ដើម្បីបំពេញមុខងារជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ÷

ក. អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមវិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ

ខ. អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការវិនិយោគទាក់ទងពាណិជ្ជកម្ម

គ. អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម

ឃ. អនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម។

**ប្រការ២.-**

អនុគណៈកម្មាធិការតាមវិស័យនីមួយៗ មានតួនាទីនិងភារកិច្ចរួម ដូចតទៅ÷

- លើកឡើងនូវរាល់វិធានការចាំបាច់ ក្នុងក្របខណ្ឌនៃការទទួលខុសត្រូវរបស់ខ្លួន ដើម្បីជំរុញការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ពិសេសលើរាល់ចំណុចពាក់ព័ន្ធទៅនឹងការអភិវឌ្ឍវិស័យឯកជន
- ពង្រឹងការអនុវត្តគោលការណ៍ **"អភិបាលកិច្ចល្អ"** នៅតាមគ្រប់ផ្នែកដែលពាក់ព័ន្ធការងារធុរកិច្ច និងការងារវិនិយោគឯកជន
- ពិភាក្សា ផ្លាស់ប្តូរយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ទាំងអ្នកផ្តល់ជំនួយ ទាំងវិនិយោគិន ទាំងធុរជន ដើម្បីលើកឡើងនូវផែនការសកម្មភាពតាមផ្នែកនីមួយៗ និងស្វែងរកប្រភពហិរញ្ញប្បទានសម្រាប់ជំរុញផែនការសកម្មភាពទាំងនោះ ឱ្យមានដំណើរការជាក់ស្តែង និងមានប្រសិទ្ធភាព
- សហការពិភាក្សាក្នុងក្របខណ្ឌអនុគណៈកម្មាធិការទាំង៤ ដើម្បីកំណត់គោលនយោបាយ និងលើកឡើងជាវិធានការដោះស្រាយ នូវរាល់ករណីដែលមិនស្ថិតក្នុងការទទួលខុសត្រូវរបស់អនុគណៈកម្មាធិការនីមួយៗ
- មានសិទ្ធិធ្វើការងារប្រទាក់ក្រឡាគ្នាជាមួយក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជនដែលមានការពាក់ព័ន្ធ។

**ប្រការ៣.-**

សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មា-ធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក អនុគណៈកម្មាធិការតាមវិស័យនីមួយៗ ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមាន អនុគណៈកម្មាធិការតាមវិស័យនីមួយៗ អាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន។

## ជំពូកទី២

## អនុគណៈកម្មាធិការបរិស្ថានវិនិយោគ

## និងការចូលរួមវិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ

**ប្រការ៥.-**

អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមវិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ មានភារកិច្ចដូចតទៅ÷

- លើកឡើងនូវរាល់វិធានការចាំបាច់បម្រើឱ្យការពង្រឹង និងកែលម្អបរិស្ថានវិនិយោគ និងធុរកិច្ច
- លើកឡើងនូវគោលនយោបាយលើកទឹកចិត្ត រៀបចំសេចក្តីព្រាង ឬ/និងពិនិត្យរាល់សេចក្តីព្រាងលិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់វិស័យឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- រៀបចំបញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ដែលទាមទារឱ្យមានការចូលរួមពីវិស័យឯកជន។

**ប្រការ៦.-**

អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមវិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៥-ប្រធាននាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | លេខាធិការ។ |

## ជំពូកទី៣

## អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការវិនិយោគទាក់ទងពាណិជ្ជកម្ម

**ប្រការ៧.-**

អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការវិនិយោគទាក់ទងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ÷

- បន្ថយរាល់បែបបទស្មុគស្មាញនិងយឺតយ៉ាវ នៅតាមបណ្តាក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធដល់ការនាំចេញ-នាំចូលរបស់ក្រុមហ៊ុន
- បំបាត់ចោលរាល់ភារកិច្ចជាន់គ្នារបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តយន្តការ **“ច្រកចេញ-ចូលតែមួយ”** នៅតាមបណ្តាច្រកទ្វារអន្តរជាតិ
- លើកឡើងនូវរាល់វិធានការចាំបាច់បម្រើឱ្យការអនុវត្តច្បាប់ បទប្បញ្ញត្តិនានាចំពោះរាល់បាតុភាពអសកម្មដែលអាចប៉ះពាល់ដល់ការងារធុរកិច្ច។

**ប្រការ៨.-**

អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្មនិងការវិនិយោគទាក់ទងពាណិជ្ជកម្មមានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |

២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប អនុប្រធាន

៤-អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុប្រធាន

៥-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក

៦-អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម លេខាធិការ។

## ជំពូកទី៤

## អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម

**ប្រការ៩.-**

អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម មានភារកិច្ចដូចតទៅ÷

- លើកគោលនយោបាយលើកទឹកចិត្តចំពោះឧស្សាហកម្មផលិតទំនិញបម្រើទីផ្សារក្នុងស្រុក ឬឧស្សាហកម្មផលិតទំនិញជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងសំណូមពរជាយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋានផលិតទំនិញក្នុងប្រទេសឱ្យបានច្រើន
- កំណត់គោលនយោបាយលើកទឹកចិត្ត និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូចនិងមធ្យម
- រៀបចំផែនការសកម្មភាពជំរុញ និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្ត
- ជំរុញការរៀបចំបទដ្ឋាននានាស្តីពីការគ្រប់គ្រងសហគ្រាសធុនតូចនិងមធ្យម
- អនុវត្តតួនាទីផ្សេងៗទៀតដែលពាក់ព័ន្ធដល់ការជំរុញ និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម។

**ប្រការ១០.-**

អនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម មានសមាសភាព ដូចខាងក្រោម÷

១-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ប្រធាន

២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣-រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១ រូប អនុប្រធាន

៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក

៥-អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម លេខាធិការ។

## ជំពូកទី៥

## អនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម

**ប្រការ១១.-**

អនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍអភិបាលកិច្ចសាជីវកម្ម សម្រាប់វិស័យមូលបត្រ និងវិស័យធុរកិច្ចពាក់ព័ន្ធដទៃទៀត

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម
- ជំរុញ តាមដាន និងវាយតម្លៃការអនុវត្តអភិបាលកិច្ចសាជីវកម្មរបស់វិស័យឯកជន
- ស្វែងរកហិរញ្ញប្បទានផ្សេងៗពីដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍអភិបាលកិច្ចសាជីវកម្មនៅកម្ពុជា
- រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីការអភិវឌ្ឍនៃអភិបាលកិច្ចសាជីវកម្ម តាមរយៈគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន។

**ប្រការ១២.-**

អនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា | អនុប្រធាន |
| ៤-អគ្គទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា ០១ រូប | អនុប្រធាន |
| ៥-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៦-ប្រធាននាយកដ្ឋាននៃគណៈកម្មការមូលបត្រកម្ពុជា ០១ រូប | លេខាធិការ។ |

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤.-**

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៧ - សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារតាមវិស័យ
# សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៣៦ សសរ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការតាមវិស័យនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- យោងតាមតម្រូវការចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.—**

ត្រូវបានបង្កើតក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន ដែលរួមមាន ១០ ក្រុមការងារ ដូចខាងក្រោម÷

ក-ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម

ខ-ក្រុមការងារផ្នែកទេសចរណ៍

គ-ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា

ឃ-ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច

ង-ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ

ច-ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ

ឆ-ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម

ជ-ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ

ឈ-ក្រុមការងារផ្នែកស្រូវ-អង្ករ

ញ-ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ។

**ប្រការ២.—**

ក្រុមការងារតាមវិស័យនីមួយៗ មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ធ្វើការប្រទាក់ក្រឡាគ្នាជាមួយគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- ពង្រឹងប្រសិទ្ធភាពនៃយន្តការ "**វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន**" ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលវិស័យឯកជនជួបប្រទះ ហើយបន្ថែមលើនេះ លើកកម្ពស់ឱ្យទៅជាយន្តការសម្រាប់ពិភាក្សាផ្តល់ជម្រើស និងអនុសាសន៍គោលនយោបាយ ដើម្បីបង្កើនតួនាទីរបស់ផ្នែកឯកជន ជាតួអង្គក្នុងកិច្ចការអភិវឌ្ឍន៍
- សហការជាមួយក្រុមការងារតាមវិស័យ នៃផ្នែកឯកជនជាដៃគូ ដើម្បីរៀបចំកម្មវិធីការងារ កំណត់ពេលប្រជុំឱ្យបានទៀងទាត់ និងផ្លាស់ប្តូរយោបល់សំដៅដោះស្រាយ រាល់បាតុភាពអសកម្ម ក៏ដូចជាសំណូមពរធុរកិច្ច ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានទាន់ពេលវេលា និង លើកជាសំណូមពរដោះស្រាយជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីចាំបាច់។ ចំពោះរាល់បញ្ហាដែលលើសពីសមត្ថកិច្ចរបស់ខ្លួន ក្រុមការងារនីមួយៗអាចលើកសំណើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល តាមរយៈអ្នកសម្របសម្រួលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- ពិនិត្យពិចារណាជាមួយវិស័យឯកជនជាដៃគូ ក្នុងការលើកឡើងនូវរាល់គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ សម្រាប់គាំទ្រលើកទឹកចិត្ត ចំពោះបណ្តាក្រុមហ៊ុនមានសកម្មភាព ក៏ដូចជាការទាក់ទាញវិនិយោគ និងធុរកិច្ចថ្មីៗបន្ថែមទៀត
- ធ្វើរបាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីសកម្មភាពការងារ ទិសដៅ និងភារកិច្ច ដែលត្រូវអនុវត្តជាបន្ត ដើម្បីមានមូលដ្ឋានសម្រាប់ប្រមុខរាជរដ្ឋាភិបាលផ្តល់អនុសាសន៍ នៅរៀងរាល់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

- ទទួលដោះស្រាយរាល់ការងារចាំបាច់ផ្សេងៗទៀត ក្នុងក្របខណ្ឌវិស័យរបស់ខ្លួន តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ច តាមវិសាលភាពការងារ ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ។

**ប្រការ៣.-**

ក្រុមការងារតាមវិស័យនីមួយៗ មានសមាសភាព ដូចខាងក្រោម÷

**ក-ក្រុមការងារវិស័យកសិកម្ម កសិ-ឧស្សាហកម្ម**

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ០១រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក។ |

**ខ-ក្រុមការងារវិស័យទេសចរណ៍**

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក។ |

**គ-ក្រុមការងារវិស័យកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា**

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក។ |

**ឃ-ក្រុមការងារវិស័យនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច**

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | សមាជិក។ |

**ង-ក្រុមការងារវិស័យសេវាធនាគារ និងហិរញ្ញវត្ថុ**

| | |
|---|---|
| ១-ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប | អនុប្រធាន |

៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

**ច-ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ**

១-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន
២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣-រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ០១រូប អនុប្រធាន
៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

**ឆ-ក្រុមការងារផ្នែកផលិតកម្មកាត់ដេរសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម**

១-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន
២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប អនុប្រធាន
៤-អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុប្រធាន
៥-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

**ជ-ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ**

១-រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន
២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប អនុប្រធាន
៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

**ឈ-ក្រុមការងារផ្នែកស្រូវ-អង្ករ**

១-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន
២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប អនុប្រធាន
៤-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

**ញ-ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ**

១-រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ប្រធាន
២-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៣-រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែល
មួយរូប ឬច្រើនរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សមាជិក។

សមាសភាពជាក់ស្តែង នៃក្រុមការងារតាមវិស័យនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.-**

ក្រុមការងារតាមវិស័យ នៃផ្នែកឯកជនជាដៃគូ ត្រូវកំណត់និងចាត់តាំងដោយសភាពាណិជ្ជកម្មកម្ពុជា។

**ប្រការ៥.-**

វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ត្រូវប្រព្រឹត្តទៅមួយឬច្រើនដង នៅរៀងរាល់ឆ្នាំ តាមការចាំបាច់។

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក ក្រុមការងារតាមវិស័យនីមួយៗ ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមាន ក្រុមការងារនីមួយៗ អាចដំណើរការប្រជុំ ក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៦.-**

ប្រធានក្រុមការងារតាមវិស័យនីមួយៗ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នផ្សេងទៀត ចូលរួមប្រជុំ ដើម្បីបំភ្លឺបញ្ហានានា តាមការចាំបាច់និងជាក់ស្តែង។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ នៃ

## សេចក្តីសម្រេចលេខ សសរ ចុះថ្ងៃទី ខែ ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

## ស្តីពី

## វិសាលភាពនៃការងារតាមផ្នែកនីមួយៗ

**ក- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម**

១- ផលិតកម្មកសិកម្មៈ ដាំដំណាំគ្រប់ប្រភេទ លើកលែងតែដំណាំដែលច្បាប់ហាមឃាត់

២- ផលិតកម្មបសុសត្វ

៣- ជលផល

៤- រោងចក្រកែច្នៃដែលប្រើប្រាស់កសិផលជាវត្ថុធាតុដើម

**ខ- ក្រុមការងារផ្នែកទេសចរណ៍**

១- រាល់សកម្មភាពពាក់ព័ន្ធវិស័យទេសចរណ៍ មានជាអាទិ៍៖ សណ្ឋាគារ ភោជនីយដ្ឋាន ភ្នាក់ងារ ទេសចរណ៍ រមណីយដ្ឋាន មណ្ឌលកំសាន្ត និងរាល់សេវាពាក់ព័ន្ធវិស័យទេសចរណ៍

២- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យទេសចរណ៍-វប្បធម៌ និងសិល្បៈ

**គ- ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា**

១- រាល់ផលិតកម្មទំនិញ សម្រាប់បម្រើតម្រូវការក្នុងស្រុក និងការនាំចេញ លើកលែងករណី ដែលមានចែងក្នុងផ្នែកផ្សេងៗនៃឧបសម្ព័ន្ធនេះ។

២- ឧស្សាហកម្មគាំទ្រ

៣- ឧស្សាហកម្មផលិតទំនិញជំនួសការនាំចូល

៤- សហគ្រាសធុនតូច និងមធ្យម

៥- សេវាកម្មអប់រំ

៦- សេវាកម្មសុខាភិបាល

៧- សេវាកម្មទូរគមនាគមន៍

៨- សេវាផ្សេងទៀត

**ឃ- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច**

១- រាល់ករណីពាក់ព័ន្ធនឹងពន្ធដារ

២- ការងារនីតិកម្ម

៣- រាល់បាតុភាពមិនប្រក្រតី ជុំវិញការបំពេញបែបបទរដ្ឋបាល នៅតាមក្រសួង-ស្ថាប័ន ក៏ដូចជាការអនុវត្តមិនត្រឹមត្រូវរបស់សហគ្រាស

៤- ពង្រឹងការអនុវត្តច្បាប់-បទប្បញ្ញត្តិនានា

**ង- ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ**

១- សេវាកម្មក្នុងក្របខ័ណ្ឌធនាគារ ហិរញ្ញវត្ថុ

២- សេវាធានារ៉ាប់រង

៣- សេវាកម្មពាក់ព័ន្ធផ្សេងៗទៀត

**ច- ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ**

១- ការសាងសង់ផ្លូវគោក ផ្លូវដែក ព្រលានយន្តហោះ កំពង់ផែ ស្ពាន...

២- សំណង់ហេដ្ឋារចនាសម្ព័ន្ធ ឬសកម្មភាពផលិត អាជីវកម្មបម្រើឱ្យកិច្ចការការពារបរិស្ថាន

៣- ការកសាងប្រព័ន្ធធារាសាស្ត្រ

៤- សេវាកម្មដឹកជញ្ជូនតាមគ្រប់មធ្យោបាយ

៥- សកម្មភាពពាក់ព័ន្ធផ្សេងៗទៀត

**ឆ- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម**

១- ឧស្សាហកម្មវាយនភ័ណ្ឌ

២- ឧស្សាហកម្មផ្សេងៗ ដែលមានទិសដៅបម្រើការនាំចេញ

៣- សកម្មភាពផលិតកែច្នៃសម្រាប់នាំចេញក្នុងតំបន់ឧស្សាហកម្ម ឬតំបន់កែច្នៃនាំចេញ ឬតំបន់ សេដ្ឋកិច្ចពិសេស

៤- ការលក់ដុំ-លក់រាយ

**ជ- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ**

១- ទីផ្សារការងារ

២- ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើតមុខរបរ

៣- ភាពសុខដុមរមនា នៃទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករ និយោជិត និងនិយោជក

**ឈ- ក្រុមការងារផ្នែកស្រូវ-អង្ករ**

១- ខ្សែសង្វាក់តម្លៃវិស័យស្រូវ-អង្ករ

២- ទីផ្សារស្រូវ-អង្ករ

**ញ- ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ**

១- ការផលិតថាមពលអគ្គិសនី និងការចែកចាយ

២- ការរុករក និងការធ្វើអាជីវកម្មប្រេង និងឧស្ម័ន

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៨ - សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តម **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ<br>អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣-ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| ៤-ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម<br>អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥-ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៧-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨-ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១០-ឯកឧត្តម **ប្រាក់ សុខុន** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១១-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១២-ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៣-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤-ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៥-ឯកឧត្តម **ហ៊ឹង ធូរ៉ាក់ស៊ី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៦-ឯកឧត្តម **សុខ ចិន្តាសោភា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី<br>អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៦៦.៧ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣

## ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យលទ្ធកម្មសាធារណៈ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានភារកិច្ចដូចតទៅ÷

- រៀបចំបង្កើត អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ត្រួតពិនិត្យនិងតាមដានលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃ
- ពិនិត្យនិងលើកយោបល់លើសំណើសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើសំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ
- ចូលរួមដោះស្រាយវិវាទលទ្ធកម្ម
- បណ្តុះបណ្តាលអំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដល់មន្ត្រីលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីពាក់ព័ន្ធដទៃទៀត អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ

២. នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ

៣. នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា

៤. នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ

៦. លេខាធិការដ្ឋាន។

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។

អង្គការលេខនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៧.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

លេខាធិការដ្ឋានដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យ ជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

## ជំពូកទី៣
## នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ

**ប្រការ៨.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងាររៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ ការងាររដ្ឋបាល បុគ្គលិក បញ្ជីកាអ្នកដេញថ្លៃ ផែនការលទ្ធកម្ម និងការងារគ្រប់គ្រងកិច្ចសន្យាលទ្ធកម្ម។

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង
- គ្រប់គ្រង ចរាចរ តម្កល់ និងថែរក្សាឯកសាររដ្ឋបាល
- គ្រប់គ្រងលិខិតបេសកកម្ម និងលិខិតចេញ ចូល
- លើកសំណើសុំ គ្រប់គ្រង និងបែងចែកសម្ភារៈ សម្រាប់ប្រើប្រាស់ក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងការងារសន្តិសុខ និងសណ្តាប់ធ្នាប់របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ធ្វើផែនការជ្រើសរើសមន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា
- លើកយោបល់លើសំណើសុំចុះបញ្ជីអ្នកដេញថ្លៃ
- លើកយោបល់អំពីការចុះបញ្ជីខ្មៅនិងការជម្រះចេញពីបញ្ជីខ្មៅអ្នកដេញថ្លៃ
- ធ្វើបច្ចុប្បន្នភាពនិងផ្សព្វផ្សាយបញ្ជីអ្នកដេញថ្លៃនិងបញ្ជីខ្មៅអ្នកដេញថ្លៃ
- សិក្សាស្រាវជ្រាវអំពីតម្រូវការនិងការវិវឌ្ឍរបស់ប្រទេសជាតិ និយាម និងនីតិវិធីល្អៗរបស់អន្តរជាតិ សម្រាប់រៀបចំកែលម្អ និងបំពេញបន្ថែមលើគោលនយោបាយលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដទៃទៀត

- រៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ
- រៀបចំសារាចរសម្រាប់ណែនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- រៀបចំ បង្កើត និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ
- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មអំពីរបៀបរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍នៃការអនុវត្តផែនការលទ្ធកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ពិនិត្យនិងវិភាគលើទិន្នន័យពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានលើការបង្កើន ឬបន្ថយកម្រិតទឹកប្រាក់សិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ចាត់ចែងបង្ហោះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ និងឯកសារលទ្ធកម្មសាធារណៈដទៃទៀត ព្រមទាំងទិន្នន័យនៃលទ្ធកម្មសាធារណៈ នៅក្នុងគេហទំព័រលទ្ធកម្មសាធារណៈ
- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម និងមន្ត្រីពាក់ព័ន្ធដទៃទៀតអំពីរបៀបបញ្ចូលឯកសារនិងទិន្នន័យលទ្ធកម្មសាធារណៈនៅក្នុងគេហទំព័រលទ្ធកម្មសាធារណៈ
- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម អំពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យា
- ត្រួតពិនិត្យនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម
- ស្រាវជ្រាវតម្លៃនិងបង្កើតតារាងស្តីពីទិន្នន័យតម្លៃនៃសមាសធាតុលទ្ធកម្ម
- រៀបចំបង្កើត គ្រប់គ្រង និងថែរក្សាទិន្នន័យលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា
- បណ្តុះបណ្តាលមន្ត្រីលទ្ធកម្ម មន្ត្រី និងអ្នកពាក់ព័ន្ធដទៃទៀត អំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ៩.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល

២. ការិយាល័យគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ

៣. ការិយាល័យផែនការ ស្ថិតិ និងព័ត៌មានវិទ្យា

៤. ការិយាល័យគ្រប់គ្រងកិច្ចសន្យា។

**ប្រការ១០.-**

ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ÷

- រៀបចំ បង្កើត កែលម្អ បំពេញបន្ថែមនូវបទបញ្ជាផ្ទៃក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

- គ្រប់គ្រង ចរាចរ តម្កល់ និងថែរក្សាឯកសាររដ្ឋបាល
- គ្រប់គ្រងលិខិតបេសកកម្មនិងលិខិតចេញ ចូល
- លើកសំណើសុំ គ្រប់គ្រង និងបែងចែកសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទ្រព្យសម្បត្តិរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងការងារសន្តិសុខនិងសណ្តាប់ធ្នាប់របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ចាត់ចែងការងារពិធីការរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីរាជការនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ធ្វើផែនការជ្រើសរើសមន្ត្រីក្របខណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ សំណង់ និងសេវាកម្មរបស់អង្គភាពស្វយ័តតាមការចាំបាច់ ដោយមានការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បណ្តុះបណ្តាលមន្ត្រីលទ្ធកម្ម មន្ត្រី និងអ្នកពាក់ព័ន្ធដទៃទៀត អំពីការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ១១.-**

ការិយាល័យគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ មានភារកិច្ចដូចតទៅ÷

- ពិនិត្យនិងវាយតម្លៃលើពាក្យសុំចុះបញ្ជី និងឯកសារពាក់ព័ន្ធរបស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ
- ពិនិត្យនិងវាយតម្លៃលើសំណើសុំតម្លើងប្រភេទ និងបន្ថែមចំណាត់ថ្នាក់របស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ
- ចាត់ចែងក្រុមការងារបច្ចេកទេសចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានទាំងឡាយ ដែលមាននៅក្នុងឯកសារភ្ជាប់របស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ
- លើកយោបល់អំពីការចុះបញ្ជី ការបែងចែកប្រភេទ ការដំឡើងប្រភេទ ការផ្តល់ចំណាត់ថ្នាក់ និងការបន្ថែមចំណាត់ថ្នាក់
- លើកយោបល់អំពីការចុះបញ្ជីខ្មៅនិងការជម្រះចេញពីបញ្ជីខ្មៅអ្នកដេញថ្លៃ
- ធ្វើបច្ចុប្បន្នភាពនិងផ្សព្វផ្សាយបញ្ជីអ្នកដេញថ្លៃនិងបញ្ជីខ្មៅអ្នកដេញថ្លៃ
- គ្រប់គ្រងប្រព័ន្ធទិន្នន័យបញ្ជីអ្នកដេញថ្លៃនិងបញ្ជីខ្មៅអ្នកដេញថ្លៃ
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ សំណង់ និងសេវាកម្មរបស់រាជធានី ខេត្ត តាមការចាំបាច់ ដោយមានការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ១២.-**

ការិយាល័យផែនការ ស្ថិតិ និងព័ត៌មានវិទ្យា មានភារកិច្ចដូចតទៅ÷

- រៀបចំ បង្កើត កែលម្អគោលនយោបាយលទ្ធកម្មសាធារណៈ

- រៀបចំ បង្កើត និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ
- រៀបចំសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មអំពីរបៀបរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងវិភាគលើទិន្នន័យពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានលើការបង្កើន ឬបន្ថយកម្រិតទឹកប្រាក់សិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យ និងលើកយោបល់លើផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍នៃការអនុវត្តផែនការលទ្ធកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- បង្ហោះសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃនិងឯកសារដេញថ្លៃ នៃកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងគេហទំព័រលទ្ធកម្មសាធារណៈ
- ចាត់ចែងបង្ហោះ លិខិតបទដ្ឋានគតិយុត្តលទ្ធកម្ម លទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម ឯកសារលទ្ធកម្មពាក់ព័ន្ធដទៃទៀត ព្រមទាំងបង្ហោះបញ្ជីអ្នកដេញថ្លៃនិងបញ្ជីខ្មៅអ្នកដេញថ្លៃនៅក្នុងគេហទំព័រលទ្ធកម្មសាធារណៈ
- រៀបចំ បង្កើត គ្រប់គ្រង និងថែរក្សាប្រព័ន្ធត្រួតពិនិត្យនិងប្រព័ន្ធសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា
- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីលទ្ធកម្មពាក់ព័ន្ធដទៃទៀតអំពីរបៀបបញ្ចូលទិន្នន័យទៅក្នុងគេហទំព័រលទ្ធកម្មសាធារណៈ
- លើកឡើងនូវយុទ្ធសាស្ត្រនិងចក្ខុវិស័យលទ្ធកម្មសាធារណៈក្នុងការប្រើប្រាស់បច្ចេកទេសព័ត៌មានវិទ្យា
- រៀបចំតភ្ជាប់បណ្តាញកុំព្យូទ័រនៅក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនិងអង្គភាពពាក់ព័ន្ធ
- សិក្សាអំពីតម្លៃទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា និងធ្វើបច្ចុប្បន្នភាពតារាងតម្លៃ
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ សំណង់ និងសេវាកម្មរបស់រដ្ឋបាលថ្នាក់ជាតិ តាមការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ១៣.-**

ការិយាល័យគ្រប់គ្រងកិច្ចសន្យា មានភារកិច្ចដូចតទៅ÷

- ផ្តល់ការប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម អំពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យា
- សហការជាមួយអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មរៀបចំផែនការគ្រប់គ្រងកិច្ចសន្យាលទ្ធកម្ម
- ត្រួតពិនិត្យនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មស្របតាមផែនការដែលបានកំណត់ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា
- ធ្វើរបាយការណ៍រៀងរាល់ពេលចុះត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងរបាយការណ៍បូកសរុប ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ

- ថែរក្សាឯកសារកិច្ចសន្យាឱ្យមានសុវត្ថិភាព
- សហការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យកិច្ចសន្យា
- រៀបចំប្រព័ន្ធទំនាក់ទំនងរវាងអ្នកម្ចាស់ការ និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងពីអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៤
## នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ

**ប្រការ១៤.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញមានភារកិច្ចដូចខាងក្រោម÷

- ណែនាំអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និងដៃគូឯកជនសាធារណៈ ឱ្យអនុវត្តត្រឹមត្រូវតាមវិធាននិងបទប្បញ្ញត្តិពាក់ព័ន្ធលទ្ធកម្មសាធារណៈ ជាធរមាន
- ពិនិត្យនិងផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មទំនិញ
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មទំនិញ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ចូលរួមត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃគម្រោងលទ្ធកម្មទំនិញ
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេស លើរាល់សំណើសុំប្រគល់កិច្ចសន្យាទំនិញដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រួតពិនិត្យរាល់កិច្ចលទ្ធកម្មទំនិញក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ក្នុងករណីដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានពុំបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មដោយឡែកណាមួយផ្សេងទៀត
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ
- ចាត់ចែងបូកសរុបរបាយការណ៍អនុវត្តលទ្ធកម្មទំនិញរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ១៥.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យលទ្ធកម្មទំនិញទី១

២. ការិយាល័យលទ្ធកម្មទំនិញទី២

៣. ការិយាល័យលទ្ធកម្មទំនិញទី៣

៤. ការិយាល័យលទ្ធកម្មទំនិញទី៤។

**ប្រការ១៦.-**

ការិយាល័យលទ្ធកម្មទំនិញទី១ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញលើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ ដែលអនុវត្តដោយក្រសួងផែនការ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងព្រះបរមរាជវាំង រដ្ឋសភា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ១៧.-**

ការិយាល័យលទ្ធកម្មទំនិញទី២ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញលើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ ដែលអនុវត្តដោយក្រសួងការពារជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងមុខងារសាធារណៈ ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍។

**ប្រការ១៨.-**

ការិយាល័យលទ្ធកម្មទំនិញទី៣ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញលើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញដែលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងធម្មការនិងសាសនា ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន អាជ្ញាធរសវនកម្មជាតិ និងគណៈកម្មការជាតិរៀបចំការបោះឆ្នោត។

**ប្រការ១៩.-**

ការិយាល័យលទ្ធកម្មទំនិញទី៤ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញដែលអនុវត្តដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

**ប្រការ២០.-**

ការិយាល័យលទ្ធកម្មទំនិញទី១ ការិយាល័យលទ្ធកម្មទំនិញទី២ ការិយាល័យលទ្ធកម្មទំនិញទី៣ និងការិយាល័យលទ្ធកម្មទំនិញទី៤ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ឬអង្គភាពរៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- ណែនាំអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន ឬអង្គភាពដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្ម របស់ខ្លួនឱ្យប្រតិបត្តិត្រឹមត្រូវតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មទំនិញ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត

- ពិនិត្យផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មទំនិញ
- ពិនិត្យនិងផ្តល់យោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មទំនិញ
- ត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃចំពោះគម្រោងលទ្ធកម្មទំនិញ
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសលើរាល់សំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មទំនិញ
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ
- ប្រមូលសរុបរបាយការណ៍អនុវត្តលទ្ធកម្មទំនិញរបស់ក្រសួង ស្ថាប័ន ឬអង្គភាពដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្មរបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ សម្រាប់បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និង ផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៥
## នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា

**ប្រការ២១.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវាមានភារកិច្ចដូចខាងក្រោម÷

- ណែនាំអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និងដៃគូឯកជនសាធារណៈ ឱ្យអនុវត្តត្រឹមត្រូវតាមវិធាននិងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធលទ្ធកម្មសាធារណៈ
- ពិនិត្យនិងផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្ម សំណង់ សេវាកម្ម និងសេវាទីប្រឹក្សាជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ចូលរួមត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃចំពោះគម្រោងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេស លើរាល់សំណើសុំប្រគល់កិច្ចសន្យាសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រួតពិនិត្យរាល់កិច្ចលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ក្នុងករណីដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានពុំបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មដោយឡែកណាមួយផ្សេងទៀត

- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ចាត់ចែងបូកសរុបរបាយការណ៍អនុវត្តលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សារបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានសំណង់និងសេវា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ២២.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យលទ្ធកម្មសំណង់និងសេវាទី១

២. ការិយាល័យលទ្ធកម្មសំណង់និងសេវាទី២

៣. ការិយាល័យលទ្ធកម្មសំណង់និងសេវាទី៣

៤. ការិយាល័យលទ្ធកម្មសំណង់និងសេវាទី៤។

**ប្រការ២៣.-**

ការិយាល័យលទ្ធកម្មសំណង់និងសេវាទី១ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយក្រសួងផែនការ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងព្រះបរមរាជវាំង រដ្ឋសភា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ២៤.-**

ការិយាល័យលទ្ធកម្មសំណង់និងសេវាទី២ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយក្រសួងការពារជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមុខងារសាធារណៈ ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍។

**ប្រការ២៥.-**

ការិយាល័យលទ្ធកម្មសំណង់និងសេវាទី៣ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងធម្មការនិងសាសនា ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន អាជ្ញាធរសវនកម្មជាតិ និងគណៈកម្មការជាតិរៀបចំការបោះឆ្នោត។

**ប្រការ២៦.-**

កាវិយាល័យលទ្ធកម្មសំណង់និងសេវាទី៤ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ។

**ប្រការ២៧.-**

ការិយាល័យលទ្ធកម្មសំណង់និងសេវាទី១ ការិយាល័យលទ្ធកម្មសំណង់និងសេវាទី២ ការិយាល័យលទ្ធកម្មសំណង់និងសេវាទី៣ និងការិយាល័យលទ្ធកម្មសំណង់និងសេវាទី៤ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ឬអង្គភាពរៀងៗខ្លួនដោយមានភារកិច្ចដូចតទៅ ÷

- ណែនាំអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន ឬអង្គភាពដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្មរបស់ខ្លួនឱ្យប្រតិបត្តិត្រឹមត្រូវតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត
- ពិនិត្យនិងផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ពិនិត្យនិងផ្តល់យោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃចំពោះគម្រោងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសលើរាល់សំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- បូកសរុបរបាយការណ៍អនុវត្តលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សា របស់ក្រសួង ស្ថាប័ន ឬអង្គភាពដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្ម របស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ សម្រាប់បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៦
## នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ

**ប្រការ២៨.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចដូចខាងក្រោម÷

- ណែនាំអង្គភាពលទ្ធកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យអនុវត្តត្រឹមត្រូវតាមវិធាននិងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធលទ្ធកម្មសាធារណៈ

- ពិនិត្យផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ចូលរួមត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃចំពោះគម្រោងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេស លើរាល់សំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្ម ដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រួតពិនិត្យរាល់កិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សាក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានពុំបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មដោយឡែកណាមួយផ្សេងទៀត
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃលើការងារគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលឃុំ សង្កាត់
- ចាត់ចែងបូកសរុបរបាយការណ៍អនុវត្តលទ្ធកម្មទំនិញ សំណង់សេវាកម្ម និងសេវាទីប្រឹក្សារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ២៩.-**

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី១

២. ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី២

៣. ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៣

៤. ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៤។

**ប្រការ៣០.-**

ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី១ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តក្រចេះ។

**ប្រការ៣១.-**

ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី២ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ និងខេត្តបាត់ដំបង។

**ប្រការ៣២.-**

ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៣ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ។

**ប្រការ៣៣.-**

ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៤ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលរាជធានីភ្នំពេញ ខេត្តកំពត ខេត្តកែប ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

**ប្រការ៣៤.-**

ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី១ ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី២ ការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៣ និងការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៤ ទទួលបន្ទុកការងារពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- ណែនាំអង្គភាពលទ្ធកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្មរបស់ខ្លួនឱ្យប្រតិបត្តិត្រឹមត្រូវតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត
- ពិនិត្យនិងផ្ទៀងផ្ទាត់គម្រោងលទ្ធកម្មដែលស្នើសុំអនុវត្តជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យនិងលើកយោបល់លើសំណើពាក់ព័ន្ធនឹងការសុំគោលការណ៍អនុវត្តវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ពិនិត្យនិងផ្តល់យោបល់លើឯកសារដេញថ្លៃគម្រោងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យការបើកសំណើដេញថ្លៃនិងការចរចាថ្លៃចំពោះគម្រោងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសលើរាល់សំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ចូលរួមត្រួតពិនិត្យការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ប្រមូលសរុបរបាយការណ៍អនុវត្តលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសលទ្ធកម្មរបស់ខ្លួន ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ សម្រាប់បញ្ជូនទៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួន ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញបំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៧
## នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ

**ប្រការ៣៥.-**

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈលើការងារត្រួតពិនិត្យនិងដោះស្រាយវិវាទពាក់ព័ន្ធលទ្ធកម្មសាធារណៈ។

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ពិនិត្យនិងសម្រេច
- ត្រួតពិនិត្យលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ធ្វើការត្រួតពិនិត្យផ្ទៃក្នុងលើនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈតាមការចាំបាច់
- ធ្វើរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យកិច្ចលទ្ធកម្មនៅរៀងរាល់ពេលនៃការចុះត្រួតពិនិត្យកិច្ចលទ្ធកម្ម និងរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ទទួលពាក្យបណ្តឹងតវ៉ាលទ្ធកម្ម
- ធ្វើការត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលមានទំនាស់
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលមានទំនាស់ ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- សហការជាមួយស្ថាប័នអនុវត្តលទ្ធកម្មលើការងារដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម
- សម្របសម្រួលជាមួយនាយកដ្ឋាន បុគ្គលិក និងផែនការ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីផ្សព្វផ្សាយលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្មតាមរយៈគេហទំព័រលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ៣៦.-**

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលថ្នាក់ជាតិ

២. ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត

៣. ការិយាល័យត្រួតពិនិត្យលទ្ធកម្មអង្គភាពស្វយ័ត

៤. ការិយាល័យអធិការកិច្ចនិងដោះស្រាយវិវាទលទ្ធកម្ម។

**ប្រការ៣៧.-**

ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលថ្នាក់ជាតិ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ លើការងារត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់ក្រសួងស្ថាប័ន។

**ប្រការ៣៨.-**

ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ លើការងារត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ៣៩.-**

ការិយាល័យត្រួតពិនិត្យលទ្ធកម្មអង្គភាពស្វយ័ត បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ លើការងារត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

**ប្រការ៤០.-**

ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលថ្នាក់ជាតិ ការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យត្រួតពិនិត្យលទ្ធកម្មអង្គភាពស្វយ័ត ទទួលបន្ទុកការងាររៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- ចូលរួមធ្វើការសិក្សាស្រាវជ្រាវអំពីយន្តការនិងនីតិវិធីនៃការត្រួតពិនិត្យកិច្ចលទ្ធកម្ម
- រៀបចំផែនការត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- ត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលបានអនុវត្តរួច និងស្ថិតក្រោមសិទ្ធិសម្រេចរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ឬអង្គភាពដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន
- ធ្វើរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យនៅរៀងរាល់ពេលនៃការចុះត្រួតពិនិត្យកិច្ចលទ្ធកម្ម និងរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

**ប្រការ៤១.-**

ការិយាល័យអធិការកិច្ចនិងដោះស្រាយវិវាទលទ្ធកម្ម បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ លើការងារដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម និងការងារត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំទម្រង់បែបបទនៃការដាក់ពាក្យប្តឹងតវ៉ា
- ទទួលពាក្យបណ្តឹងតវ៉ាលទ្ធកម្ម
- ធ្វើការត្រួតពិនិត្យលើកិច្ចលទ្ធកម្មដែលមានទំនាស់
- ធ្វើការត្រួតពិនិត្យផ្ទៃក្នុងលើការិយាល័យនៃនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ តាមការចាំបាច់
- សហការជាមួយស្ថាប័នអនុវត្តលទ្ធកម្មលើការងារដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម

- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយបណ្ដឹងតវ៉ានិងវិវាទលទ្ធកម្ម
- ត្រួតពិនិត្យកិច្ចលទ្ធកម្មដែលបានអនុវត្តរួចនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ធ្វើរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យនៅរៀងរាល់ពេលនៃការចុះត្រួតពិនិត្យកិច្ចលទ្ធកម្ម និងរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៨

## លេខាធិការដ្ឋាន

**ប្រការ៤២.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការផ្ទាល់ឱ្យអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដោយមានភារកិច្ចដូចតទៅ÷

- សម្របសម្រួលការងារផ្ទៃក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងសម្របសម្រួលការងាររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាមួយនឹងអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលការងារពាក់ព័ន្ធលទ្ធកម្មសាធារណៈជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិផ្សេងទៀត
- គ្រប់គ្រងត្រារបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- រៀបចំបង្កើតនិងគ្រប់គ្រងបណ្ណាល័យលទ្ធកម្មសាធារណៈ
- រៀបចំឯកសារ សេចក្ដីព្រាងសំណើ និងសំណុំលិខិតផ្សេងៗ ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈពិនិត្យនិងសម្រេច
- រៀបចំ ចងក្រង ថែរក្សារាល់ឯកសារនានាតាមការចាំបាច់ របស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- រៀបចំ ចាត់ចែងសម្របសម្រួលការប្រជុំផ្សេងៗ និងធ្វើកំណត់ហេតុប្រជុំ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់លេខាធិការដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បូកសរុបរបាយការណ៍សកម្មភាពការងាររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ព្រាងរបាយការណ៍លទ្ធកម្មបូកសរុបប្រចាំឆ្នាំដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈសម្រាប់ផ្ញើ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**ប្រការ៤៣.-**

ក្នុងការបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៤៤.-**

ប្រកាសលេខ ២៩៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៣

## អង្គការលេខរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
Ministry of Industry, Mines and Energy
លេខ : ១១០០ ឧ.ស.ម-ក.ស-ប្រក.

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៤១២/១៣ គ.វ.ក ចុះថ្ងៃទី១៦.១០.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស្មាតសាន់ ហូលឌីង (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី០៨.១០.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ស្មាតសាន់ ហូលឌីង (ខេមបូឌា) អិលធីឌី (SMARTSON HOLDINGS (CAMBODIA) LTD.) តំណាងដោយ លោក KO SEK YAN សញ្ជាតិ ចិន អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ HA9080868 ចុះថ្ងៃទី១៧.០៣. ២០០៦ មានអាសយដ្ឋាន បច្ចុប្បន្នៈ House 460, Tomson Gold Villa, 1 Long-Dong Avenue, Pudong, Shanghai, People's Republic of China, 201203 ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១. សម្លៀកបំពាក់ (កាត់ដេរ) | ១៤១០ |
| ២. សម្លៀកបំពាក់ (ចាក់) | ១៤៣០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរ-ចាក់សម្លៀកបំពាក់ ស្មាតសាន់ ហ្វូលឌីង (ខេមបូឌា) អិលធីឌី "*

**ទីតាំងរោងចក្រ៖** *" ភូមិព្រែកសំរោង ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរ ឲ្យបានធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ នៅពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីស្តីទីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ១១៦១ ឧរថ.ភន្ត-ប្រក.

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២១៣៩/១៣ គ.វ.ក ចុះថ្ងៃទី១២.០៩.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យ័ន ស៊ិន ស្រេដ (ខេមបូឌា) ចុះថ្ងៃទី០៥.០៩.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន យ័ន ស៊ិន ស្រេដ (ខេមបូឌា) (YUAN XIN THREAD (CAMBODIA) CO., LTD.) តំណាងដោយ លោក CHEN JIANGSHENG សញ្ជាតិ ចិន អាយុ៥២ឆ្នាំ កាន់លិខិតឆ្លងដែនលេខG55259631 ចុះថ្ងៃទី១៩.០៩.២០១១ មានអាសយដ្ឋាននៅផ្ទះ Room 1504, Block7, Runzhu Yuan, Shizhu Xinhuayuan, Shi, Guangdong, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-អំបោះដេរ | ១៣១១ |
| ២-ពុម្ពស្បែកជើង | ១៥២០ |
| ៣-កែងស្បែកជើង | ១៥២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រខាអំបោះ ផលិតពុម្ពស្បែកជើង និងកែងស្បែកជើង យ៉ន ស៊ិន ស្រេដ (ខេមបូឌា) "*

**ទីតាំងរោងចក្រ៖** *" ផ្លូវថ្មី ភូមិព្រៃព្រីងជើង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ នៅពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣

**ឌ.រដ្ឋមន្ត្រីស្តីទីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ